មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម
មកដល់ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦
លេខ ១៩៣
ម៉ោង ព្រឹក៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ: ៧០៤ សជណ.កស**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ:** ករណីសំណើសុំសម្រួលនិងបន្ថែមមុខងារភារកិច្ចជូននាយកដ្ឋានគ្រឿងយន្តកសិកម្ម ឱ្យទៅជានាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មលើការងារចាត់ចែង និងដោះស្រាយទឹកក្នុងក្របខ័ណ្ឌសហគមន៍កសិកម្ម សម្រាប់បម្រើការងារបង្កបង្កើនផលកសិកម្ម។

**យោង:** - លិខិតលេខ៣៩៣៤ កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- ចំណារ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាល ឯកភាពដូចខាងក្រោម៖

១-កែសម្រួលពីឈ្មោះនាយកដ្ឋានគ្រឿងយន្តកសិកម្មឱ្យទៅជានាយកដ្ឋានវិស្វកម្មកសិកម្ម

២-បន្ថែមមុខងារនិងភារកិច្ចចំនួនបីចំណុចសម្រាប់នាយកដ្ឋានវិស្វកម្មកសិកម្មថ្មីរួមមាន៖

- សិក្សាពីលទ្ធភាព និងបំពាក់បច្ចេកវិទ្យាទំនើបក្នុងការផ្គត់ផ្គង់ទឹកសម្រាប់បម្រើដល់ការដាំដុះដំណាំរួមផ្សំ សាកវប្បកម្ម ដំណាំបន្លែ និងការចិញ្ចឹមសត្វនិងវារីវប្បកម្ម នៅតាមសហគមន៍កសិកម្ម ដែលត្រូវបានបង្កើតឡើង ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីទាញយកទឹកតាមរយៈការសាងសង់ប្រឡាយជើងក្អែប ការជីកអណ្តូង ការបូម និងតាមមធ្យោបាយផ្សេងៗទៀត បម្រើឱ្យសហគមន៍កសិកម្មក្នុងការដាំដុះប្រពលវប្បកម្មដំណាំ ពិពិធភាវូបនីយកម្ម និងការលើកកម្ពស់ផលិតភាពកសិកម្ម
- ចូលរួមធ្វើអន្តរាគមន៍ក្នុងការដោះស្រាយបញ្ហាទឹកជូនដល់កសិករ ក្នុងពេលកសិករជួបប្រទះនឹងបញ្ហាប្រឈមទៅនឹងគ្រោះធម្មជាតិដូចជារាំងស្ងួត និងទឹកជំនន់ ដែលកើតចេញពីបម្រែបម្រួលអាកាសធាតុ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប៊ុន - អ៊ុយ

**ចម្លងជូន:**
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងធនធានទឹកនិងឧតុនិយម
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
-ឯកសារ-កាលប្បវត្តិ

លេខ ១៦៦៣ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមលិខិតលេខ៧០៥ សជណ.កស
ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងបញ្ជូនមកៈ

- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
" ដើម្បីជូនជ្រាប "
- ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត
" ដើម្បីជ្រាប និងមុខការ"

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**ត.ប រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

ឡោ វុទ្ធី